ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៩៥

ចុះថ្ងៃទី១៣-០២-២០០៣

សាលដីកា

លេខ:១១៧ "ខ"

ចុះថ្ងៃទី២០-១២-២០០៦

# នាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ:០៦ក្រចុះថ្ងៃទី០៨-០២-១៩៩៣បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី២០-ធ្នូ-២០០៦ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៩៥ចុះថ្ងៃទី១៣-០២-២០០៣រវាង:

**ជនជាប់ចោទ:**

១-ឈ្មោះ [redacted] រ៉េត ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] សុវណ្ណ មានកូន០៣នាក់ ទោសពីមុនជាប់គុក១៣ឆ្នាំ(ក្នុងឃុំ)ប្តឹងឧទ្ធរណ៍)

២-ឈ្មោះ [redacted] ឃុំ ភេទប្រុស អាយុ៤២ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃដូចខាងលើ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនជាប់ពន្ធនាគា១០ឆ្នាំ(គេចខ្លួន)។

៣-ឈ្មោះ [redacted] ចេស ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិ [redacted] ។ឪពុកឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន(គេចខ្លួន)

៤-ឈ្មោះ [redacted] ជួន ភេទប្រុសអាយុ៣៥ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន។(ឃុំ១០.៤.០២)





Scanned with CamScanner

៥-ឈ្មោះ [redacted] ហេន ភេទប្រុសអាយុ ៥៧ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃដូចខាងលើ។ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៧នាក់ ទោសពីមុន ជាប់ពន្ធនាគារ០៩ ឆ្នាំ ចាប់ខ្លួនថ្ងៃទី១៨.០៩.២០០១ ឃុំខ្លួនបន្ត។

៦-ឈ្មោះ [redacted] ធិន ភេទប្រុស អាយុ៨៣ឆ្នាំជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ ដូចខាងលើ។ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស)ប្រពន្ធឈ្មោះ [redacted] មានកូន០៧នាក់ ទោសពីមុនគ្មានចាប់ ខ្លួនថ្ងៃទី៣១.០៧.២០០១ ឃុំខ្លួនថ្ងៃទី០២.៩.២០០២។

ជាប់ចោទពីបទៈ អំពើភេរវកម្ម ប្រព្រឹត្តនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៨.០៧.២០០១។មាត្រា០២ នៃច្បាប់អំពីភេរវកម្ម។

១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted] មុខរបរធ្វើស្រែ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០៨ នាក់ ទោសពីមុនគ្មាន។

## ឯរឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ចុះថ្ងៃទី ២៨.៧.២០០១ ថា កាលពីថ្ងៃទី២៣.៧.២០០១ ម៉ោង១២.១៥នាទី យប់មានចោរមួយក្រុមមានគ្នា០៥នាក់ អាវុធ០២ដើម បានឡើងមកលើផ្ទះចាប់ចងខ្លួន និងកូន០៣នាក់ បណ្តើរយកទៅកន្លែងវត្តចាស់ បង្ខាប់យកប្រាក់០២លាន់រៀល។ចោរបានលែងខ្លួនឲ្យមករកលុយទៅលោះ ខ្លួនក៏ទៅរាយការណ៍ឲ្យរដ្ឋអំណាចប៉ុស្តិ៍ចុះធ្វើអន្តរាគមន៍ លែងកូនខ្លួនមកផ្ទះទាំងអស់ដោយសុវត្ថភាព។សុំតុលាការផ្តន្ទាទោសតាមច្បាប់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី១៦-តុលា-២០០២ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោមៈ

១-ផ្តន្ទាទោសឈ្មោះ [redacted] រ៉ាត ភេទប្រុសអាយុ៣២ឆ្នាំរត់គេចខ្លួន។

-ឈ្មោះ [redacted] ឃុំ ភេទប្រុស អាយុ៤២ឆ្នាំ រត់គេចខ្លួន

-ឈ្មោះ [redacted] ធិន ភេទប្រុសអាយុ៨៣ឆ្នាំ

-ឈ្មោះ [redacted] ហេន ភេទប្រុសអាយុ៥៧ឆ្នាំ

ដាក់ពន្ធនាគាក្នុងម្នាក់ៗ១០ឆ្នាំ ពីបទអំពើ ភេរវកម្ម ប្រព្រឹត្តនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៨.៧.២០០១ តាមបញ្ញត្តិមាត្រា២នៃ ច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្មទោសនេះគិតចាប់ពីថ្ងៃផុតអនុវត្តសាលក្រមព្រហ្មទណ្ឌលេខ១៧ ចុះថ្ងៃទី២៩.០១.២០០២ តទៅ។

២-ផ្តន្ទាទោសឈ្មោះ [redacted] ជួន ភេទប្រុស អាយុ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ក្នុងចំនួន ១០ឆ្នាំ (ដប់ឆ្នាំ)ពីបទ អំពើភេរវកម្ម ប្រព្រឹត្តិនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៨.៧.០១ តាមបញ្ញត្តិមាត្រា២នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម។

ទោសនេះគិតចាប់ពីថ្ងៃចាប់ខ្លួនបាន ថ្ងៃទី០៩.៨.២០០២តទៅ។



Scanned with CamScanner

៣-សម្រេចឲ្យឈ្មោះ [redacted] ចេស រួចខ្លួនពីបទចោទប្រកាន់អំពីភេរវកម្ម ប្រព្រឹត្តនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៩.៧.២០០១ តាមបញ្ញត្តិមាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted]និន ឈ្មោះ [redacted]ហេន ឈ្មោះ [redacted] ជូន និងមេធាវីការពារឲ្យជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទឈ្មោះ [redacted]កែត ឈ្មោះ [redacted]យ៉ុ ទុកសិទ្ធិប្តឹងទាស់ និង ប្តឹង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់

-បានឃើញរបាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី ២៦.១០.២០០៥

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី០៩.១០.២០០៣

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)

### តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

សំណុំរឿងនេះជនជាប់ចោទមានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់ ដូចនេះសុំលោកចៅក្រមតម្កល់សាលក្រមត្រង់ចំណុចទី១,២,និង ៤ ទុកជាបានការ និងសុំបដិសេធចំណុចទី៣នៃសេចក្តីសម្រេចក្នុងសាលក្រមចោលជាអសាបង់សុំផ្តន្ទាទោសជាថ្មីលើជនល្មើសឈ្មោះ [redacted] ចេស ពីបទ: អំពើភេរវកម្ម តាមមាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម។

-លោក [redacted] សុវណ្ណាលី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនទទួលស្គាល់អំពើប្រព្រឹត្តដែលបានចោទប្រកាន់អស់ហើយ ដូចនេះនៅពេលនេះសំណូមពរសុំសាលាឧទ្ធរណ៍បន្ធូបន្ថយទោសឲ្យកូនក្តីខ្លួនតាមច្បាប់។

-លោក [redacted] រាសីភ័ក្រ្ត ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា:ចម្លើយរបស់កូនក្តីខ្លួនមានលក្ខណៈច្បាស់លាស់ហើយនៅពេលនេះសុំធ្វើសំណូមពរសុំសាលាឧទ្ធរណ៍បន្ធូបន្ថយទោសឲ្យកូនក្តីខ្លួនតាមច្បាប់។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ



Scanned with CamScanner

# សាលាឧទ្ធរណ៍

## យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍លេខ៨៨ចុះថ្ងៃទី១៦-១០-២០០២ របស់ព្រះរាជអាជ្ញារងអមតុលាការខេត្តកំពង់ធំ

-បណ្ដឹងឧទ្ធរណ៍លេខ ៥៣ ចុះថ្ងៃទី០២-១២-២០០២ របស់ជនជាប់ចោទឈ្មោះ [redacted] ជួន , [redacted] ឆិន , [redacted] ហេន និងលេខ ០៨ ចុះថ្ងៃទី១២-០១-២០០៣ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាត ធ្វើឡើងនៅក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះនៅសមត្ថកិច្ចតាមមាត្រា១៧៨ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] ឆិន និងឈ្មោះ [redacted] ហេន ថាខ្លួនមិនបានចូលរួមក្នុងសកម្មភាពភេរវកម្ម ចាប់ជំរិតកាលពីខែ៧.២០០១ នោះទេហើយឈ្មោះ [redacted] ឆិន ថាឈ្មោះ [redacted] ចេស មិនបានចូលរួមក្នុងសកម្មភាពនោះទេដែរ។ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] ជួន ថាក្រុមចាប់ជំរិតនៅភូមិព្រៃស្រង៉ែមានគ្នា៥នាក់មានឈ្មោះ ខ្លួន [redacted] ជួន,[redacted] ឆិន,[redacted] ហេន,[redacted] យ៉ុ,និង [redacted] វ៉ាត។ ចំណែកជនជាប់ចោទឈ្មោះ [redacted] វ៉ាត ថាក្រុមខ្លួនចាប់មនុស្សជំរិតយកប្រាក់ បានប្រព្រឹត្តចាប់មនុស្សជំរិតទារប្រាក់ចំនួន៧លើក ដែលក្នុង៧លើកនោះមានថ្ងៃទី២៨,៧,០១ នោះដែរហើយក្នុងការធ្វើសកម្មភាពចាប់ជំរិតទាំង៧លើករួមទាំងថ្ងៃទី២៨,៧,០១ នៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ សុទ្ធតែមានឈ្មោះ [redacted] ឆិន, [redacted] ហេន និង [redacted] ចេស ចូលរួមធ្វើសកម្មភាពមិនដែលខានទេ ហើយតាមរបាយការណ៍លេខ ០០៣.០៣.១០.០៣ របស់អធិការនគបាលស្រុកបារាយណ៍ ថាឈ្មោះ [redacted] ចេស ក៏ជាអ្នកសកម្មក្នុងអំពើភេរវកម្មដែរ។ដូច្នេះអាចបញ្ជាក់បានថាឈ្មោះ [redacted] ឆិន,[redacted] ហេន និងជាពិសេសឈ្មោះ [redacted] ចេស ពិតជាបានចូលរួមធ្វើសកម្មភាពចាប់ជំរិតទារយកប្រាក់ ប្រព្រឹត្តនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ប្រាកដមែន។

៣-មានភស្តុតាងបញ្ជាក់ពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ [redacted] ចេស ភេទប្រុសអាយុ៣៣ឆ្នាំជាតិខ្មែរមុខរបរធ្វើស្រែ សព្វថ្ងៃនៅភូមិផ្លូវទ្រាស ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ពីបទអំពើភេរវកម្មប្រព្រឹត្តនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៨,៧,០១ បទល្មើសមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា២នៃច្បាប់ស្ដីពីការផ្ដន្ទាទោសអំពើភេរវកម្ម។

៤-សាលក្រមព្រហ្មទណ្ឌលេខ១៥២ ចុះថ្ងៃ១៦.១០.០២របស់តុលាការខេត្តកំពង់ធំសម្រេចមានលក្ខណៈសមស្របគួរតម្កល់ទុកជាបានការលើកលែងតែចំណុចទី៣ នៃសេចក្ដីសម្រេចគួរបដិសេធចោល ហើយសម្រេចឡើងវិញដូចការយល់ឃើញខាងលើ ក្រៅពីនេះគួររក្សាទុកនៅដដែល។



Scanned with CamScanner

# ហេតុដូច្នេះ
# វិនិច្ឆ័យសេចក្តី

១-ក/ទទួលបណ្តឹងឧទ្ធរណ៍លេខ៨៨ ចុះថ្ងៃទី១៦-១០-២០០២របស់លោកព្រះរាជអាជ្ញារងអមតុលាការខេត្តកំពង់ធំ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

ខ/ទទួលបណ្តឹងឧទ្ធរណ៍លេខ៥៣ ចុះថ្ងៃទី០២-១២-២០០២ របស់ជនជាប់ចោទឈ្មោះ [redacted] ជូន, [redacted] ជិន, [redacted] ហេន និងលេខ២០៨ ចុះថ្ងៃ១២,០១,០៣ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៥២ ចុះថ្ងៃទី១៦.១០.០២របស់សាលាដំបូងខេត្តកកំពង់ធំទុកជាបានការលើកលែងតែចំណុចទី៣ត្រូវបដិសេធចោលជាអសាបង់។

៣-ផ្តន្ទាទោសឈ្មោះ [redacted] ចេស អាយុ៣៣ឆ្នាំជាតិខ្មែរ មុខរបរធ្វើស្រែ សព្វថ្ងៃមានទីលំនៅភូមិផ្លូវទ្រាស ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដាក់ពន្ធនាគាកំណត់១០ឆ្នាំ ពីបទអំពើភេរវកម្ម ប្រព្រឹត្តនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៨.៧.០១ បទល្មើសមានចែងនិងផ្តន្ទាទោសតាមមាត្រា២នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម។

៤-សាលដីកានេះនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទកំបាំងមុខជនជាប់ចោទ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

សាលដីកានេះប្រកាសចូលជាស្ថាពរតែលើជនជាប់ចោទឈ្មោះ ហ ហេន ម្នាក់ប៉ុណ្ណោះ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ភ្នំពេញ, ថ្ងៃទី២៣ ខែ៤ ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]